ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៩២ សប្តាហ៍ទី ២ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

48:033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស។

ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

០៨-១២-២០០៧ -ព្រះរាជក្រម នស/រកម/១២០៧/០៣៤ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដើម្បីតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ ៩៧០២

២. ព្រះរាជក្រឹត្យ

០៨-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦០២ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះនាយទាហានជាន់ខ្ពស់ចំនួន ៧២ រូប ៩៧៤៤

០៨-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦០៤ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ មានឋានៈស្មើរដ្ឋលេខាធិការ ៩៧៤៦

០៨-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦០៥ ស្តីពីការតែងតាំងឯកឧត្តម និងលោកជំទាវ ចំនួន ០៣ រូប ជា សមាជិកបម្រុងក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈ រដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក ៩៧៤៧

០៨-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦០៦ ស្តីពីការតែងតាំងលោកជំទាវ និងឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សា ឯកឧត្តម **ហេង សំរិន** អនុប្រធានទី ២ រដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើអនុរដ្ឋលេខាធិការ ៩៧៤៨

០៨-១២-២០០៧ -ព្រះរាជក្រឹត្យនស/រកត/១២០៧/៦០៧ ស្តីពីការបញ្ចប់តំណែងលោកជំទាវ **ម៉ែន គ្រីស្នែន** ពីទីប្រឹក្សា ឯកឧត្តម **ហេង សំរិន** អនុប្រធានទី ២ នៃរដ្ឋសភានីតិកាលទី ៣ ៩៧៤៩

០៨-១២-២០០៧ -ព្រះរាជក្រឹត្យនស/រកត/១២០៧/៦០៨ ស្តីពីការតែងតាំងឯកឧត្តម **សុខ សារាវុទ្ធ** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩៧៥០

០៨-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦០៩ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត ចំនួន ០២ រូប ៩៧៥១

០៨-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦១០ ស្តីពីការបន្ថយទោសរយៈពេលរងទោសចំនួន ៩ ខែអោយទណ្ឌិតឈ្មោះ ម៉េង ឫក ៩៧៥២

០៩-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦១១ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រីតាមលក្ខន្តិកៈដោយឡែក នូវ មន្ត្រីរាជការស៊ីវិលរបស់ក្រសួងទេសចរណ៍ ចំនួន ១៦០ នាក់ ៩៧៥៣

II.ក្រុមប្រឹក្សាធម្មនុញ្ញ

០៧-១២-២០០៧ -សេចក្តីសំរេចលេខ ៤៤/២០០៧ កបធ.សសរ ស្តីពីវិសោធនកម្មប្រការ ៣ ប្រការ ៦ ប្រការ ៨ ថ្មី ប្រការ ១០ ថ្មី និង ប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ៩៧៦២

III.រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៣-១២-២០០៧ -អនុក្រឹត្យ លេខ ១៩៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៩៧៦៥

០៦-១២-២០០៧ -អនុក្រឹត្យ លេខ ៥៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៩៧៦៧

០៦-១២-២០០៧ -អនុក្រឹត្យ លេខ ៥៥៨ អនក្រ.តត ស្តីពីការផ្លាស់ប្តូរភារកិច្ចមន្ត្រីរាជការ ៩៧៦៨

១៣-១២-២០០៧ -អនុក្រឹត្យ លេខ ៥៥៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៧៦៩

១៤-១២-២០០៧ -អនុក្រឹត្យ លេខ ៥៦០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៩៧៧២

១៤-១២-២០០៧ -អនុក្រឹត្យ លេខ ៥៦១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៩៧៧៣

IV.ការិយាល័យក្រសួង

១.ទីស្តីការក្រសួងមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៧-១២-២០០៧ -ប្រកាសលេខ ១២៣២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ីអិនអ៊ីហ្វូតវែរ បង្កើតរោងចក្រ " ផលិតស្បែកជើង " ដែលមានឈ្មោះថា " អេស៊ីអិនអ៊ីហ្វូតវែរ " ៩៧៧៤

០៧-១២-២០០៧ -ប្រកាសលេខ ១២៣៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឌុង សុង អ៊ិនធើណេសិនណល បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ឌុង សុង អ៊ិនធើណេសិនណល " ៩៧៧៦

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងកិច្ចការនារី

ប្រកាស

០៤-១២-២០០៧ -ប្រកាសលេខ ០៩៥ កកន/ប្រក ស្តីពីការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ខេត្ត-ក្រុង ៩៧៧៨

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្វាយនែនសល ស៊ីស្ទឹម សឺវីស អ៊ីន** ៩៧៨២

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ែតវ៉ានស៍ កុំព្យូទ័រ& អេឡិកត្រូនិក** ៩៧៨៤

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី អេច រោយ ហូថេល អេន រីហ្សត (ខេមបូឌា)** ៩៧៨៦

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណារ៉ាឡៃ គ្រីអេសិន** ៩៧៨៨

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.ធី.អ៊ែកស៍** ៩៧៩០

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូសូហ្វ ថេកណូឡូជី** ៩៧៩២

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូ រោយ ធី** ៩៧៩៤

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៦៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាយ៉នរាលអ៊ីស្តេត ផនប្រូយ៉ះ** ៩៧៩៦

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ាងទុន (ខេមបូឌា) ខូ អិលធីឌី** ៩៧៩៧

២៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ១២៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិន.ស៊ី.អិច.ឆោរទី ប្រូឌុស ខូ អិលធីឌី** ៩៧៩៩

ព្រះរាជក្រម

នស/រកម/១២០៧/០៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ សម្រាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្ដីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
ក្របខ័ណ្ឌសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ សម្រាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ ដែលធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ

ប្រមុខរដ្ឋស្ដីទី

នស.០៧១២.២៧៦

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

លេខ ៥៧៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ
នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាល
ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលនៃប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ

ដោយរំលឹក ដល់កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េដែលបានចុះហត្ថលេខានៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ នៅកូឡាឡាំពួ ម៉ាឡេស៊ី

ដោយរំលឹកថែមទៀត ដល់មាត្រា ១.៣ និង ២.១ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលឆ្លុះបញ្ចាំងការសន្យារបស់ខ្លួនក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - កូរ៉េ ដែលគ្របដណ្តប់ពាណិជ្ជកម្មទំនិញ

ដោយបញ្ជាក់ឡើងវិញ ការសន្យាលុបចោលពន្ធនាំចូល និងបទបញ្ញត្តិរឹតត្បិតពាណិជ្ជកម្មលើពាណិជ្ជកម្មទំនិញស្ទើរតែទាំងអស់រវាងប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េនៅក្នុងរយៈពេលបានកំណត់ ទោះជាមានការផ្តល់ភាពទន់ភ្លន់ដល់ភាគីដើម្បីដោះស្រាយវិស័យរសេបិត ដូចមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ និង

ដោយទទួលស្គាល់ តួនាទីកាតព្វកិច្ចនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរវាងប្រទេសសមាជិកអាស៊ាន និងសេចក្តីត្រូវការភាពទន់ភ្លន់ដែលត្រូវផ្តល់ឱ្យប្រទេសសមាជិកអាស៊ានថ្មី ជាពិសេសសេចក្តីត្រូវការដើម្បីសម្រួលការចូលរួមច្រើនឡើងក្នុងសហប្រតិបត្តិការសេដ្ឋកិច្ចនៃបណ្តាភាគី និងការពង្រីកការនាំចេញរាប់បញ្ចូលទាំងការពង្រឹងភាពអាចប្រជែងបាន ប្រសិទ្ធិភាព និងសមត្ថភាពក្នុងស្រុក

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ ÷

មាត្រា ១

និយមន័យ

ដើម្បីគោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែបរិបទតម្រូវផ្សេងពីនេះ ៖

អេអ៊ីអឹម+ កូរ៉េ មានន័យថា រដ្ឋមន្ត្រីសេដ្ឋកិច្ចនៃប្រទេសសមាជិកអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មកូរ៉េ

អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុត (MFN) :

ក- សំរាប់ប្រទេសសមាជិកអាស៊ានដែលជាសមាជិក WTO រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ និងកូរ៉េ មានន័យថា អត្រាពន្ធអនុវត្តរៀងៗខ្លួនរហូតដល់ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ និង

ខ- សំរាប់ប្រទេសសមាជិកអាស៊ានដែលមិនមែនជាសមាជិក WTO រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ គឺអត្រាពន្ធដែលអនុវត្តចំពោះកូរ៉េរហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥

អាស៊ាន មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលមាន ប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយម វៀតណាម ។

តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ មានន័យថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងពាក់ព័ន្ធទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រាទី ១៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

បណ្តាប្រទេសសមាជិកអាស៊ាន មានន័យថា ប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិប តេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមរួមគ្នា ។

ប្រទេសសមាជិកអាស៊ាន មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមនិមួយៗ ។

អាស៊ាន ៦ មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម សាធារណរដ្ឋឥណ្ឌូណេស៊ី ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី និងព្រះរាជាណាចក្រថៃឡង់ដ៍ ។

កិច្ចព្រមព្រៀងក្របខ័ណ្ឌ មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាល នៃប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ ។

GATT ១៩៩៤ មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីអត្រាពន្ធ និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ រាប់បញ្ចូលទាំងអត្ថបទ និងបទបញ្ញត្តិបន្ថែមដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀង នៃអង្គការពាណិជ្ជកម្មពិភពលោក ។

គណៈកម្មការអនុវត្តន៍ មានន័យថា គណៈកម្មការអនុវត្តន៍បង្កើតឡើងក្រោមមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

កូរ៉េ មានន័យថា សាធារណរដ្ឋកូរ៉េ

ប្រទេសសមាជិកអាស៊ានថ្មី មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

បណ្តាវិធានមិនមែនពន្ធ រួមមានទាំងរបាំងមិនមែនពន្ធ ។

បណ្តាភាគី មានន័យថា បណ្តាប្រទេសអាស៊ាន និងកូរ៉េរួមគ្នា ។

WTO មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក ។

កិច្ចព្រមព្រៀងរបស់ WTO មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេសដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ធ្វើនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៤ និងបណ្តាកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចរចាក្រោមកិច្ច ព្រមព្រៀងនេះ ។

មាត្រា ២
ប្រព្រឹត្តិកម្មជាតិទៅលើទំនិញ និងការយកពន្ធក្នុងស្រុក

ភាគីនីមួយៗត្រូវផ្តល់ប្រព្រឹត្តិកម្មជាតិទៅឱ្យទំនិញនៃបណ្តាភាគីទាំងអស់ស្របតាមមាត្រា ៣ នៃ GATT 1994។ ដូចនេះបទបញ្ញត្តិនៃមាត្រា III នៃកិច្ចព្រមព្រៀង GATT 1994 និងត្រូវបញ្ចូល និងគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀង នេះ ។

មាត្រា ៣
ការលុប និងការបន្ថយពន្ធនាំចូល

១ - ការបន្ថយ ឬកម្មវិធីលុបពន្ធនៃបណ្តាភាគីនឹងតម្រូវឱ្យអត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតលើផលិតផល ដែលមានក្នុងបញ្ជីបន្ថយជាបន្តបន្ទាប់ និងបើអាច លុបចោលស្របតាមមាត្រានេះ ។

២ - បន្ទាត់ពន្ធគយទាំងអស់ត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌនៃកម្មវិធីកាត់បន្ថយ ឬលុបពន្ធក្រោមកិច្ចព្រមព្រៀងនេះនឹងត្រូវ បែងចែកដូចខាងក្រោមនេះ ÷

ក- ប្រភេទធម្មតា : អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតនៃបន្ទាត់ពន្ធគយដែលភាគីនីមួយៗ បានដាក់ក្នុងប្រភេទធម្មតាដោយខ្លួនឯងត្រូវបន្ថយ និងលុបបំបាត់ស្របតាមរបៀបកំណត់ក្នុងឧបសម្ព័ន្ធ ១ ក្នុងគោលដៅសំរេចឱ្យបាននូវកំរិតទាបបំផុតនៃទិសដៅ។

ខ- ប្រភេទរសើប : អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតដែលភាគីនីមួយៗ បានដាក់បញ្ចូលក្នុងប្រភេទ រសើបដោយខ្លួនឯងត្រូវបន្ថយ ឬលុបបំបាត់ទៅតាមរបៀបកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។

៣- ស្ថិតនៅក្រោមល័ក្ខខ័ណ្ឌនៃឧបសម្ព័ន្ធ ១ និង ២ រាល់ការសន្យាដែលបានធ្វើដោយភាគីនីមួយៗ ក្រោមមាត្រានេះ ត្រូវអនុវត្តទៅភាគីទាំងឡាយដទៃទៀត។

មាត្រា ៤
តម្លាភាព

មាត្រាទី ១០នៃកិច្ចព្រមព្រៀង GATT ឆ្នាំ1994 និងត្រូវបញ្ចូល និងគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

មាត្រា ៥
វិធានដើមកំណើតទំនិញ

វិធានដើមកំណើតទំនិញ និងនីតិវិធីនៃការចេញវិញ្ញាបនប័ត្រដែលអាចអនុវត្តទៅលើទំនិញនៃកិច្ចព្រមព្រៀងនេះមានចែងនៅក្នុងឧបសម្ព័ន្ធ ៣ និងឯកសារភ្ជាប់ជាមួយឧបសម្ព័ន្ធ។

មាត្រា ៦
ការកែប្រែសម្បទាន

១- បណ្ដាភាគីមិនត្រូវលុបចោល ឬ រារាំងសម្បទានណាមួយនៃកិច្ចព្រមព្រៀងនេះ លើកលែងតែករណីដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង។

២ - គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះហាមឃាត់ភាគីណាមួយមិនឱ្យចរចា និងចុះហត្ថលេខាលើកិច្ចសំរុះសំរួលដើម្បីពន្លឿនការអនុវត្តន៍សម្បទានដែលបានធ្វើក្រោមកិច្ចព្រមព្រៀងនេះ ឬបញ្ចូលទំនិញថ្មីទៅក្នុងសម្បទានឱ្យតែកិច្ចសំរុះសំរួលខាងលើនេះត្រូវបានធ្វើឡើងដោយការឯកភាពទៅវិញទៅមក និងត្រូវអនុវត្តទៅលើភាគីទាំងអស់។

៣- ភាគីណាក៏ដោយ តាមរយៈការចរចា និងការព្រមព្រៀងគ្នាជាមួយភាគីណាមួយផ្សេងទៀតដែលត្រូវផ្ដល់សម្បទានអាចកែប្រែ ឬដកហូតសម្បទានខាងលើដែលបានធ្វើក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងការចរចា និងការព្រមព្រៀងនេះដែលរាប់បញ្ចូលទាំងការផ្ដល់ការប៉ះប៉ូវចំពោះទំនិញផ្សេងទៀត បណ្ដាភាគីពាក់ព័ន្ធត្រូវរក្សាកំរិតទូទៅនៃសម្បទានដែលមានផលប្រយោជន៍ទៅវិញទៅមកចំពោះពាណិជ្ជកម្ម មិនទាបជាងសម្បទានដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះមុនការព្រមព្រៀង ។

៤- ការព្រមព្រៀងណាមួយដោយបណ្តាភាគីដើម្បីកែប្រែ ឬដកហូតសម្បទានដែលបានធ្វើតាមកម្មវិធីនៃការលុប ឬបន្ថយពន្ធនាំចូលស្របតាមកថាខ័ណ្ឌ ៣ ឬដើម្បីពន្លឿនការលុបពន្ធនាំចូលនៅក្នុងកម្មវិធីខាងលើ ឬដើម្បីបញ្ចូលទំនិញទៅក្នុងកម្មវិធីខាងលើស្របតាមកថាខ័ណ្ឌ ២ ត្រូវជំនួសអត្រាពន្ធ ឬផ្លូវដែលបានកំណត់អនុលោមតាមកម្មវិធីនៃការលុបសំរាប់ទំនិញនោះ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ និង ២ ត្រូវធ្វើដូចវិសោធនកម្មនៃឧបសម្ព័ន្ធពាក់ព័ន្ធ ហើយត្រូវចូលជាធរមានស្របតាមនីតិវិធីនៃមាត្រា ១៧ ។

មាត្រា ៧
វិន័យនៃអង្គការពាណិជ្ជកម្មពិភពលោក

ស្ថិតក្រោមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងនានាដែលអាចឯកភាពអនុលោម ការសើរើនៃកិច្ចព្រមព្រៀងនេះដោយភាគីទាំងឡាយនៃមាត្រា ១៥ ភាគីនានាឯកភាព និងបញ្ជាក់ឡើងវិញតាមរយៈមាត្រានេះ នូវការសន្យាគោរពបទបញ្ញត្តិនៃវិន័យនៃអង្គការពាណិជ្ជកម្មពិភពលោកដូចមានកំណត់ក្នុងឧបសម្ព័ន្ធ 1 A និង 1 C នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកដូចមានរាយក្នុងឧបសម្ព័ន្ធ ៤ ដែលរាប់បញ្ចូលក្នុងចំណោមនោះ វិធានការមិនមែនពន្ធរបាំងបច្ចេកទេសពាណិជ្ជកម្ម ខាងក្រោយនេះ (ហៅថា TBT) វិធានការអនាម័យ និងភូតគាមអនាម័យ (ខាងក្រោមនេះហៅថា SPS) វិធានការប៉ះប៉ូវ វិធានប្រឆាំងនឹងការលក់បន្ថោកថ្លៃ និងសិទ្ធិកម្មសិទ្ធិបញ្ញា ។

មាត្រា ៨
វិធានការរឹតត្បិតបរិមាណ វិធានការមិនមែនពន្ធ និង វិធានការអនាម័យ និង ភូតគាមអនាម័យ

១- ភាគីនីមួយៗប្តេជ្ញាចិត្តមិនអនុម័ត ឬរក្សាការហាមឃាត់ ឬការរឹតត្បិតបរិមាណណាមួយលើការនាំចូលទំនិញណាមួយរបស់ភាគីនានាផ្សេងទៀត ឬលើការនាំចេញទំនិញណាមួយសំដៅទៅដែនដីនៃភាគីទាំងឡាយផ្សេងទៀត លើកលែងតែស្របតាមសិទ្ធិ និងកាតព្វកិច្ចនៃអង្គការពាណិជ្ជកម្មពិភពលោក ឬបទបញ្ញត្តិទាំងឡាយផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ ។

២ - ភាគីនីមួយៗ ត្រូវធានាតម្លាភាពនៃវិធានការមិនមែនពន្ធ តែគេមិនបានរៀបចំអនុម័ត ឬអនុវត្តដើម្បីបង្កើតឧបសគ្គមិនចាំបាច់ដល់ពាណិជ្ជកម្មនៃភាគីទាំងឡាយ។ ភាគីនានាត្រូវរកឱ្យឃើញរបាំងមិនមែនពន្ធក្រៅពីការរឹត

ត្បិតបរិមាណដើម្បីបំបាត់យ៉ាងលឿនបំផុតក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ រយៈពេលនៃការបំបាត់របាំងមិនមែនពន្ធត្រូវឯកភាពគ្នាទៅវិញទៅមកដោយភាគីទាំងអស់ ។

៣- ភាគីទាំងឡាយទទួលស្គាល់សារៈសំខាន់នៃតម្លាភាពរបស់បទបញ្ញា TBT និង SPS ដូចមានចែងក្នុងកិច្ចព្រមព្រៀងទាំងឡាយ និងអង្គការពាណិជ្ជកម្មពិភពលោកស្តីពី TBT និង SPS រាប់បញ្ចូលទាំងនីតិវិធីនៃការជូនដំណឹងអំពីការរៀបចំបទបញ្ញា និងស្តង់ដាររបស់ TBT និងអំពីការកើតឡើងនៃករណី SPS ដើម្បីបន្ថយឥទ្ធិពលអវិជ្ជមានរបស់វាមកលើពាណិជ្ជកម្ម ព្រមទាំងការការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ។ ភាគីនីមួយៗត្រូវចាត់តាំងចំណុចទំនាក់ទំនងដើម្បីឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធដល់មាត្រានេះ។

៤- ក្រុមការងារស្តីពី TBT និង SPS (ខាងក្រោយនេះហៅថាក្រុមការងារ TBT និង SPS) នៅក្រោមគណៈកម្មការអនុវត្ត នឹងត្រូវបង្កើតឡើងដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធដល់ការអនុវត្តន៍នៃមាត្រានេះ និងសំរួលពាណិជ្ជកម្ម និងការពារជីវិត និងសុខភាព មនុស្ស សត្វ និងរុក្ខជាតិ តាមរយៈសហប្រតិបត្តិការទៅវិញទៅមក និងការពិគ្រោះទ្វេភាគី។ ក្រុមការងារ TBT និង SPS មានសមាសភាពមន្ត្រីរដ្ឋាភិបាល ពីទីភ្នាក់ងារកសិកម្ម នេសាទ ការចិញ្ចឹមសត្វ និងសុខាភិបាល និងទីភ្នាក់ងារពាក់ព័ន្ធទាំងឡាយទៀត។ ក្រុមការងារ TBT និង SPS នេះត្រូវរៀបចំទំហំការងារ និងផែនសកម្មភាពរបស់ខ្លួន និងជួបជុំគ្នាយ៉ាងតិចបំផុតម្តងក្នុងមួយឆ្នាំ តាមការឯកភាពគ្នាទៅវិញទៅមកដោយភាគីនានា។

មាត្រា ៩

វិធានការការពារ

១- ភាគីនីមួយៗដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក រក្សាសិទ្ធិ និងកាតព្វកិច្ចក្រោមមាត្រា ១៩ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ។ សកម្មភាពនានាដែលធ្វើស្របតាមមាត្រាទី ១៩ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងនៃ អង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ពុំស្ថិតក្រោមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទក្រោម កិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

២- ចំពោះវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ភាគីមានសិទ្ធិផ្តួចផ្តើមវិធានការបែបនេះសំរាប់ទំនិញនៅក្នុងរយៈពេលអន្តរកាលសំរាប់ទំនិញនោះ ។ រយៈពេលអន្តរកាលសំរាប់ទំនិញត្រូវចាប់ផ្តើមពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងបញ្ចប់ ៧ ឆ្នាំក្រោយពីការបញ្ចប់ការកាត់បន្ថយ ឬការលុបចោលពន្ធនាំចូលសំរាប់ទំនិញនោះ ។

៣- ស្ថិតក្រោមល័ក្ខខ័ណ្ឌនៃកថាខ័ណ្ឌខាងក្រោមនៃមាត្រានេះ ភាគីមានសិទ្ធិចាត់វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បើឥទ្ធិពលនៃការបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងសម្បទានពន្ធនាំចូល ឬបើលទ្ធផលនៃព្រឹត្តិការណ៍ដែលមិនបានគ្រោងទុក និងនៃឥទ្ធិពលរបស់កាតព្វកិច្ចដោយភាគី ទំនិញកំពុងនាំចូលពីភាគីទាំងឡាយផ្សេងទៀត និងដែលបានទទួលសម្បទានពន្ធនាំចូល ក្នុងបរិមាណកើនឡើងបើប្រៀបទៅនឹងផលិតផលក្នុងស្រុក ហើយក្រោមល័ក្ខខ័ណ្ឌដែលបង្ក ឬគំរាមកំហែង និងបង្កយ៉ាងខ្លាំងក្លានូវការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនៃប្រទេសនាំចូលដែលផលិតផលិតផលដូចគ្នា ឬផលិតផលប្រកួតប្រជែងនៅក្នុងដែនដីរបស់ខ្លួន ។

៤ - បើវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ត្រូវបានចាត់ ភាគីដែលចាត់វិធានការនេះត្រូវ :

ក- ព្យួរការបន្ថយថែមទៀតនៃពន្ធនាំចូលនៃទំនិញដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

ខ- បង្កើនពន្ធនាំចូលនៃទំនិញពាក់ព័ន្ធទៅដល់កំរិតដែលមិនលើសពី :

- អត្រាពន្ធអនុវត្ត MFN លើទំនិញជាធរមាននៅពេលដែលសកម្មភាពត្រូវបានចាត់
- អត្រាពន្ធអនុវត្ត MFN លើទំនិញជាធរមាននៅកាលបរិច្ឆេទមុនបន្ទិច កាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

៥ - វិធានការការពារណាមួយនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ អាចរក្សាទុកសំរាប់រយៈពេលបឋម ៣ ឆ្នាំ និងអាចពន្យារសំរាប់រយៈពេលមិនលើស ១ ឆ្នាំ បើវិធានការនោះត្រូវបានកំណត់ស្របតាមនីតិវិធីចែងនៅក្នុងកថាខ័ណ្ឌ ៦ ថា វិធានការនោះនៅតែចាំបាច់សំរាប់បង្ការ និងជួសជុលការខូចខាតធ្ងន់ធ្ងរ និងដើម្បីសំរួលការកែតម្រូវ និងត្រូវមានភ័ស្តុតាងបញ្ជាក់ថាឧស្សាហកម្មក្នុងស្រុកកំពុងធ្វើការកែតម្រូវ ។ ទោះជាមានរយៈកាលនៃវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េក៏ដោយ ក៏វិធានការនេះត្រូវបញ្ចប់នៅទីបញ្ចប់នៃរយៈពេលអន្តរកាលសំរាប់ទំនិញនោះ ។

៦ - ក្នុងការអនុវត្តន៍នៃវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បណ្តាភាគីត្រូវអនុម័តវិធានសំរាប់ការអនុវត្តន៍ វិធានការការពារ រាប់បញ្ចូលទាំងវិធានការបណ្តោះអាសន្នដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង WTO ស្តីពីការការពារ លើកលែងតែវិធានការរឹតត្បិតបរិមាណដែលមានចែងនៅក្នុងមាត្រា ៥ និង មាត្រា ៩ ១៣ ១៤ នៃកិច្ចព្រមព្រៀង WTO ស្តីពីការការពារ ។ តាមរបៀបនេះ រាល់បទបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀង WTO ស្តីពីការការពារ តាមការជាក់ស្តែង ត្រូវបញ្ចូលទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

៧- វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ មិនត្រូវអនុវត្តប្រឆាំងនឹងទំនិញដែលមានដើមកំណើតពីដែនដីនៃភាគី ដរាបណាចំណែកនាំចូលទំនិញនោះនៅក្នុងប្រទេសនាំចូលមិនលើស ៣% នៃការនាំចូលសរុបពីបណ្តាភាគី។

៨- ក្នុងការស្វែងរកការប៉ះប៉ូវក្រោមមាត្រា ៨ នៃកិច្ចព្រមព្រៀង WTO ស្តីពីការការពារសំរាប់វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បណ្តាភាគីពាក់ព័ន្ធត្រូវស្វែងរកអន្តរាគមន៍សំរុះសំរួលនៃគណៈកម្មការអនុវត្តដើម្បីកំណត់កំរិតសម្បទានសំខាន់ប្រហាក់ប្រហែលទៅនឹងកំរិតដែលមានស្រាប់ក្រោមកិច្ចព្រមព្រៀងនេះ រវាងភាគីដែលចាត់វិធានការការពារ និងភាគីនាំចេញទាំងឡាយដែលរងផលប៉ះពាល់ដោយវិធានការនេះមុនការព្យួរសម្បទានណាមួយដែលប្រហាក់ប្រហែល។ ទម្រង់ការនៃអន្តរាគមន៍សំរុះសំរួលត្រូវបញ្ចប់ក្នុងរយៈពេល ៩០ ថ្ងៃពីកាលបរិច្ឆេទដែលវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េត្រូវបានអនុវត្ត។

៩- ផ្អែកលើការប្តេជ្ញាចិត្តរបស់ភាគីនៃវិធានការការពារលើទំនិញនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ អត្រាពន្ធសំរាប់ទំនិញនោះគឺជាអត្រាពន្ធដែលគួរបានចូលជាធរមាន ក៏ប៉ុន្តែដោយសារការចាត់វិធានការការពារមិនបានចូលជាធរមាន ស្របតាមកម្មវិធីនៃការលុបបំបាត់ និងកាត់បន្ថយពន្ធរបស់ភាគីដូចមានចែងក្នុងឧបសម្ព័ន្ធ ១ និង ២។

១០ - ទោះជាមានបទបញ្ញត្តិនៃមាត្រានេះ គ្មានភាគីណាមួយអាចចាត់វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ទៅលើទំនិញដែលការប្តឹងតវ៉ាកំពុងដំណើរការស្របទៅតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ។ នៅពេលភាគីណាមួយមានបំណងអនុវត្តអនុលោមតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ការប្តឹងតវ៉ាលើ

ទំនិញ ដែលវិធានការការពារពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ កំពុងដំណើរនឹងត្រូវបញ្ឈប់មុនការប្តឹងតវ៉ាស្របតាម XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ។

១១ - រាល់លិខិតទំនាក់ទំនង និងសំណុំឯកសារផ្លូវការដែលបានផ្លាស់ប្តូរក្នុងចំណោមបណ្តាភាគី និងទៅគណៈកម្មការ អនុវត្តនូវរាល់ការពាក់ព័ន្ធ វិធានការការពារពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ត្រូវតែជាលាយល័ក្ខអក្សរ និងត្រូវជាភាសាអង់គ្លេស ។

មាត្រា ១០
វិធានការការពារជញ្ជីងទូទាត់

នៅពេលដែលភាគីជួបការលំបាកធ្ងន់ធ្ងរខាងជញ្ជីងទូទាត់ ឬហិរញ្ញវត្ថុក្រៅប្រទេស ឬការគំរាមកំហែងចេញពីនោះ យោងតាមកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ ភាគីអាចអនុម័តវិធានការរឹតត្បិតលើការនាំចូលដែលរាប់បញ្ចូលទាំងកិច្ចសំរុះសំរួលស្តីពីបទបញ្ញត្តិនៃជញ្ជីងទូទាត់នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤។ នៅក្នុងការអនុម័តវិធានការបែបនេះ ភាគីត្រូវពិគ្រោះជាបន្ទាន់ជាមួយភាគីដទៃទៀត ។

មាត្រា ១១
ការលើកលែងជាទូទៅ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីរារាំងការអនុម័ត ឬការអនុវត្តន៍ដោយភាគីនូវវិធានការ តែស្ថិតនៅក្រោមការតំរូវថា វិធានការទាំងនោះមិនត្រូវបានអនុវត្តដើម្បីបង្កើតជាការរើសអើងដោយអំពើ ឬមិនអាចដោះស្រាយបានក្នុងចំណោមភាគីទាំងឡាយ នូវពេលដែលល័ក្ខខ័ណ្ឌដូចគ្នាកើតមានឡើង ឬការរឹតត្បិតជាក់លាក់លើពាណិជ្ជកម្មអន្តរជាតិ :

ក- ចាំបាច់សំរាប់ការពារសីលធម៌សាធារណៈ

ខ- ចាំបាច់សំរាប់ការពារសុខភាព និងជីវិតមនុស្ស សត្វ និងរុក្ខជាតិ

គ- ពាក់ព័ន្ធដល់ការនាំចូល និងនាំចេញ មាស ឬប្រាក់

ឃ- ចាំបាច់ដើម្បីធានាការគោរពច្បាប់ ឬបទបញ្ជាដែលមិនស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងច្បាប់ ឬបទបញ្ជាទាក់ទងដល់ការអនុវត្តន៍ច្បាប់ ឬបទបញ្ជាគយ ការអនុវត្តនីងកសិទ្ធិក្រោមកថាខ័ណ្ឌ ៤ នៃមាត្រា ២ និងមាត្រា ១៧ នៃកិច្ចព្រមព្រៀង GATT 1994 ការការពារប៉ាតង់ ពាណិជ្ជសញ្ញា ឬសិទ្ធិចម្លង និងការបង្ការអំពើបំពាន

ង- ទាក់ទងទៅនឹងផលិតផលនៃពលកម្មពន្ធនាគារ

ច- ដាក់ដើម្បីការពារសម្បត្តិជាតិដែលមានតម្លៃខាងបុរាណវិទ្យា ប្រវត្តិសាស្ត្រ និង សិល្បៈ

ឆ- ទាក់ទងដល់ការរក្សាធនធានធម្មជាតិដែលមិនអាចកើតឡើងវិញបាន បើវិធានការបែបនេះ ត្រូវបានចាត់ស្របតាមការរឹតត្បិតលើការប្រើប្រាស់ និងផលិតកម្មក្នុងស្រុក

ជ- ចាត់ស្របតាមកាតព្វកិច្ចនៃកិច្ចព្រមព្រៀងទំនិញអន្តររដ្ឋាភិបាលណាមួយដែលគោរពតាមលក្ខណៈវិនិច្ឆ័យដែលត្រូវបញ្ជូនទៅឱ្យអង្គការពាណិជ្ជកម្មពិភពលោកពិនិត្យ និងមិនត្រូវបានបដិសេធ ឬត្រូវបានបញ្ជូនទៅដោយខ្លួនឯងនឹងមិនត្រូវបានបដិសេធ

ឈ- ទាក់ទងដល់ការរឹតត្បិតការនាំចេញវត្ថុធាតុក្នុងស្រុកចាំបាច់ដើម្បីធានាបរិមាណចាំដុំនៃវត្ថុធាតុដើមនេះសំរាប់ឧស្សាហកម្មកែច្នៃក្នុងស្រុក ក្នុងរយៈពេលដែលតម្លៃក្នុងស្រុកនៃវត្ថុធាតុដើមនេះត្រូវបានកំណត់ទាបជាងតម្លៃពិភពលោកដែលជាផ្នែកមួយនៃផែនការស្ថេរកម្មរដ្ឋាភិបាលសំរាប់
ដរាបណាការរឹតត្បិតនេះមិនធ្វើឡើងដើម្បីបង្កើនការនាំចេញ ឬការពារឧស្សាហកម្មក្នុងស្រុកនេះ និងមិនប្រាកចាកពីបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះពាក់ព័ន្ធទៅនឹងការមិនរើសអើង

ញ- ចាំបាច់ដល់ការទិញ ឬដល់ការចែកចាយផលិតផលនៃការផ្គត់ផ្គង់មានការខ្វះខាតជាទូទៅ ឬក្នុងស្រុក ដរាបណាវិធានការបែបនោះស្របតាមគោលការណ៍ភាគីទាំងអស់មានសិទ្ធិទៅ និងចំណែកយុត្តិធម៌នៃការផ្គត់ផ្គង់អន្តរជាតិនៃផលិតផលនោះ ហើយវិធានការបែបនេះដែលស្របតាមបទបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះត្រូវបានបញ្ឈប់នៅពេលដែលល័ក្ខខ័ណ្ឌនៃការចាត់វិធានការលែងមានទៀតហើយ ។

មាត្រា ១២
ការលើកលែងខាងសន្តិសុខ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយ :

ក- ទាមទារឱ្យភាគីណាមួយផ្តល់ព័ត៌មានដែលការប្រាប់ឱ្យដឹង ត្រូវបានចាត់ទុកថាផ្ទុយទៅនឹងផលប្រយោជន៍សន្តិសុខយ៉ាងសំខាន់

ខ- រារាំងភាគីណាមួយពីការធ្វើសកម្មភាពដែលចាត់ទុកថាចាំបាច់សំរាប់ការពារផលប្រយោជន៍ខាងសន្តិសុខសំខាន់រាប់បញ្ចូលទាំង តែមិនកំណត់ត្រឹម :

១-សកម្មភាពទាក់ទងដល់វត្ថុធាតុបរមាណូ និងវត្ថុធាតុចេញពីនេះ

២- សកម្មភាពទាក់ទងដល់ការជួញដូរអាវុធ គ្រាប់រំសេវ និង ឧបករណ៍សង្គ្រាម និងការជួញដូរទំនិញ និងវត្ថុធាតុផ្សេងទៀតដែលធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលដើម្បីគោលដៅផ្គត់ផ្គង់យោធា

៣-សកម្មភាពធ្វើឡើងដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍សំខាន់ពីការប៉ុនប៉ងជាក់លាក់ធ្វើឱ្យលែងប្រើការបាន ឬធ្វើឱ្យអន់ថយហេដ្ឋារចនាសម្ព័ន្ធនេះ

៤-សកម្មភាពដែលធ្វើនៅពេលសង្គ្រាម ឬក្នុងករណីបន្ទាន់ក្នុងទំនាក់ទំនងជាតិ ឬអន្តរជាតិ

គ - រារាំងភាគីណាមួយពីការធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនៃធម្មនុញ្ញសហប្រជាជាតិសំរាប់ការរក្សាសន្តិភាពអន្តរជាតិ និងសន្តិសុខ ។

មាត្រា ១៣
រដ្ឋាភិបាលតំបន់ និង មូលដ្ឋាន

ក្នុងការសំរេចកាតព្វកិច្ច និងការសន្យានៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធានាការគោរពដោយរដ្ឋាភិបាល និងអាជ្ញាធរតំបន់ និងមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន ព្រមទាំងការគោរពដោយអង្គភាពមិនមែនរដ្ឋាភិបាល ក្នុងការប្រើអំណាចផ្តល់ឱ្យដោយរដ្ឋាភិបាល ឬអាជ្ញាធរកណ្តាល តំបន់ និងមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន ។

មាត្រា ១៤
កិច្ចសំរុះសំរួលស្ថាប័ន

បណ្តាស្ថាប័នដូចមានចែងក្នុងមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវត្រួតពិនិត្យ សំរបសំរួល និងពិនិត្យឡើងវិញនៅពេលណាសមស្រប ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

មាត្រា ១៥
ការពិនិត្យឡើងវិញ

១- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកូរ៉េ ឬតំណាងរបស់ខ្លួនត្រូវជួបជុំគ្នាម្តងនៅក្នុងឆ្នាំនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ បន្ទាប់មកពីរឆ្នាំម្តង ឬផ្សេងពីនេះ តាមការសមស្រប ដើម្បីពិនិត្យឡើងវិញកិច្ចព្រមព្រៀងនេះក្នុងទិសដៅគិតគូរបន្ថែមទៀតនូវវិធានការដើម្បីធ្វើសេរីកម្មពាណិជ្ជកម្មទំនិញព្រមទាំងរបៀបវិន័យ និងចរចាកិច្ចព្រមព្រៀងអំពីបញ្ហាដូចមានចែងក្នុងមាត្រា ៧ ឬបញ្ហាពាក់ព័ន្ធផ្សេងទៀតទៅតាមការឯកភាពគ្នា ។

២ - ដោយផ្អែកលើបទពិសោធន៍រៀងៗខ្លួននៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវពិនិត្យឡើងវិញទំនិញរសើបនៅឆ្នាំ ២០១២ និងក្រោយមកទៀតរៀងរាល់ ៣ឆ្នាំ ម្តង ដើម្បីធ្វើអោយប្រសើរល័ក្ខខ័ណ្ឌនៃការបើកទីផ្សារទំនិញរសើប រាប់បញ្ចូលទាំងលទ្ធភាពនៃការបន្ថយថែមទៀតនូវបរិមាណទំនិញរសើប និងល័ក្ខខ័ណ្ឌណែនាំប្រព្រឹត្តកម្មអគ្រាពន្ធទៅវិញទៅមកនៃទំនិញដែលភាគីបានដាក់ក្នុងប្រភេទរសើប ។

មាត្រា ១៦
ឧបសម្ព័ន្ធ និងលិខិតុបករណ៍នៅអនាគត

១ - ឧបសម្ព័ន្ធ និងសេចក្តីបន្ថែមទាំងឡាយគឺជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ។

២- បណ្តាភាគីអាចអនុម័តលិខិតុបករណ៍នៅពេលខាងមុខ ស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។ ផ្អែកលើចូលជាធរមានរៀងៗខ្លួន លិខិតុបករណ៍ទាំងនេះគឺជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ។

មាត្រា ១៧
វិសោធនកម្ម

បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះអាចកែប្រែតាមរយៈវិសោធនកម្មដែលបានឯកភាពគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយបណ្ដាភាគី ។

មាត្រា ១៨

ទំនាក់ទំនងទៅកិច្ចព្រមព្រៀងផ្សេងទៀត

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងនេះ ឬសកម្មភាពណាមួយដែលបានធ្វើក្រោមកិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ ឬធ្វើឱ្យមោឃៈសិទ្ធិ និងកាតព្វកិច្ចនៃភាគីក្រោមកិច្ចព្រមព្រៀងនានាដែលមានស្រាប់ ដែលភាគីនោះជាហត្ថលេខី ។

មាត្រា ១៩

ការដោះស្រាយវិវាទ

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ វិវាទពីការបកស្រាយ ការអនុវត្តនៃកិច្ចព្រមព្រៀងនេះត្រូវដោះស្រាយតាមរយៈនីតិវិធី និងយន្តការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្ដីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

មាត្រា ២០

កន្លែងតម្កល់ទុកឯកសារ

សំរាប់ប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះត្រូវរក្សាទុកដោយអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្ដល់ច្បាប់បញ្ជាក់ទៅគ្រប់ប្រទេសសមាជិកអាស៊ាន ។

មាត្រា ២១

ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ ដរាបណា យ៉ាងហោចណាស់ ប្រទេសសមាជិកអាស៊ានមួយៗ និងកូរ៉េដែលក្នុងចំណោមប្រទេសហត្ថលេខីបានជូនពត៌មាននៅពេលនោះទៅភាគីផ្សេងទៀតទាំងអស់ជាលាយល័ក្ខអក្សរអំពីការបញ្ចប់បែបបទក្នុងស្រុក ។ ក្នុងករណីដែលកិច្ចព្រមព្រៀងនេះមិនអាចចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទី ០១ នៃខែទី ០២ បន្ទាប់ពីកាលបរិច្ឆេទខាងដើម ដែលនៅពេលនោះយ៉ាងហោចណាស់ប្រទេសអាស៊ានមួយ និងកូរ៉េបានជូនពត៌មានទៅគ្រប់ភាគីទាំងអស់ផ្សេងទៀតជាលាយល័ក្ខអក្សរអំពីការបញ្ចប់នីតិវិធីក្នុងស្រុក ។

២ - ភាគីត្រូវជូនពត៌មានទៅភាគីផ្សេងទៀតទាំងអស់ជាលាយល័ក្ខអក្សរនៅពេលបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

៣- នៅពេលដែលភាគីមិនអាចបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ តាមកាលបរិច្ឆេទកំណត់ក្នុងកថាខ័ណ្ឌទី ១ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានសំរាប់ភាគីនោះនៅកាលបរិច្ឆេទនៃការជូនដំណឹងពីការបញ្ចប់នីតិវិធីក្នុងស្រុក ។ ប៉ុន្តែភាគីពាក់ព័ន្ធត្រូវគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះរាប់បញ្ចូលទាំងការសន្យាថែមទៀត ដែលបានធ្វើឡើងដោយភាគីផ្សេងទៀតក្រោមកិច្ចព្រមព្រៀងនេះ នៅពេលជូនពត៌មាននេះ ហាក់ដូចជាភាគីពាក់ព័ន្ធនេះបានជូនពត៌មានទៅភាគីផ្សេងទៀតជាលាយល័ក្ខអក្សរអំពីការបញ្ចប់នីតិវិធីក្នុងស្រុកមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

ជាសក្ខីភាព ហត្ថលេខីខាងក្រោមដោយមានការអនុញ្ញាតិស្របច្បាប់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនេះ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ។

ធ្វើនៅកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ជាពីរច្បាប់ជាភាសាអង់គ្លេស ។

សំរាប់រដ្ឋាភិបាលប្រ៊ូណេដារ៉ូសាឡឹម

លឹម ជក សេង
រដ្ឋមន្ត្រីទី២ នៃក្រសួងការបរទេស និងពាណិជ្ជកម្ម

សំរាប់រាជរដ្ឋាភិបាលកម្ពុជា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
សំរាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី

ម៉ារី អែលកា ប៉េងជីទូ
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

ណាំ វីយាកេត
រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលម៉ាឡេស៊ី

រ៉ាហ្វីដា អាស៊ីស
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសភាពមីយ៉ាន់ម៉ា

ស៊ុ ចាំ
រដ្ឋមន្ត្រីក្រសួងផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ផីតធី ប៊ី ហ្វាវិឡា
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋសឹង្ហបូរី

លីម អ៊ុង គៀង
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលថៃឡង់ដ៍

សំគីត ចាទូរីពីតាក់
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីពាណិជ្ជកម្ម

AGREEMENT ON TRADE IN GOODS UNDER THE FRAMEWORK AGREEMENT ON COMPREHENSIVE ECONOMIC COOPERATION AMONG THE GOVERNMENTS OF THE MEMBER COUNTRIES OF THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE REPUBLIC OF KOREA

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Vietnam, Member Countries of the Association of Southeast Asian Nations and the Republic of Korea,

RECALLING the Framework Agreement on Comprehensive Economic Cooperation among the Governments of the Member Countries of the Association of Southeast Asian Nations and the Republic of Korea signed in Kuala Lumpur, Malaysia on the thirteenth day of December 2005;

FURTHER RECALLING Articles 1.3 and 2.1 of the Framework Agreement, which reflect their commitment to establish the ASEAN-Korea Free Trade Area covering trade in goods;

REAFFIRMING their commitment to eliminate duties and other restrictive regulations of commerce on substantially all trade in goods among the ASEAN Member Countries and the Republic of Korea within the specified time frames, while allowing flexibility to them to address their sensitive areas as provided in the Framework Agreement; and

RECOGNISING the different stages of economic development among the ASEAN Member Countries and the need for flexibility to be given to the new ASEAN Member Countries, in particular the need to facilitate their increasing participation in the economic cooperation of the Parties and the expansion of their exports, including, *inter alia*, through strengthening of their domestic capacity, efficiency and competitiveness,

HAVE AGREED as follows:

Article 1
Definitions

1. For the purposes of this Agreement, unless the context otherwise requires:

AEM + Korea means the Economic Ministers of the ASEAN Member Countries and the Minister for Trade of Korea;

applied MFN tariff rates:

(a) in the case of the ASEAN Member Countries which are WTO members as of 1 January 2005 and Korea, means their respective applied rates as of 1 January 2005; and

(b) in the case of ASEAN Member Countries which are non-WTO members as of 1 January 2005, refer to the rates as applied to Korea as of 1 January 2005;

ASEAN means the Association of Southeast Asian Nations which comprises of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Vietnam;

ASEAN–Korea FTA means the ASEAN-Korea Free Trade Area established by the Framework Agreement and other relevant agreements stipulated in paragraph 1 of Article 1.4 of the Framework Agreement;

ASEAN Member Countries means Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Vietnam collectively;

ASEAN Member Country means Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand or the Socialist Republic of Vietnam individually;

ASEAN 6 means Brunei Darussalam, the Republic of Indonesia, Malaysia, the Republic of the Philippines, the Republic of Singapore and the Kingdom of Thailand;

Framework Agreement means the Framework Agreement on Comprehensive Economic Cooperation among the Governments of the ASEAN Member Countries and the Republic of Korea;

GATT 1994 means the General Agreement on Tariffs and Trade 1994, including its Notes and Supplementary Provisions, which is a part of the WTO Agreement;

Implementing Committee means the Implementing Committee established under Article 5.3 of the Framework Agreement;

Korea means the Republic of Korea;

new ASEAN Member Countries means the Kingdom of Cambodia, the Lao Peoples' Democratic Republic, the Union of Myanmar and the Socialist Republic of Vietnam;
non-tariff measures shall include non-tariff barriers;

Parties means the ASEAN Member Countries and Korea collectively;

Party means an ASEAN Member Country or Korea;

WTO means the World Trade Organisation; and

WTO Agreement means the Marrakesh Agreement Establishing the World Trade Organisation, done on 15 April 1994 and the other agreements negotiated thereunder.

Article 2
National Treatment on Internal Taxation and Regulation

Each Party shall accord national treatment to the goods of all the other Parties in accordance with Article III of GATT 1994. To this end, the provisions of Article III of GATT 1994 shall, *mutatis mutandis*, be incorporated into and form an integral part of this Agreement.

Article 3
Tariff Reduction and Elimination

1. The tariff reduction or elimination programme of the Parties shall require the applied MFN tariff rates on goods under listed tariff lines to be gradually reduced and, where applicable, eliminated in accordance with this Article.

2. All tariff lines are subject to the tariff reduction or elimination programme under this Agreement and shall be categorised as follows:

(a) Normal Track: tariff lines placed in the Normal Track by each Party on its own accord shall have their respective applied MFN tariff rates gradually reduced and eliminated in accordance with the modalities set out in Annex 1 with the

objective of achieving the targets prescribed in the thresholds therein; and

(b) Sensitive Track: tariff lines placed in the Sensitive Track by each Party on its own accord shall have their respective applied MFN tariff rates reduced or eliminated in accordance with the modalities set out in Annex 2.

3. Subject to Annexes 1 and 2, all commitments undertaken by each Party under this Article shall be applied to all the other Parties.

Article 4
Transparency

Article X of GATT 1994 shall, *mutatis mutandis*, be incorporated into and form an integral part of this Agreement.

Article 5
Rules of Origin

The Rules of Origin and the Operational Certification Procedures applicable to the goods covered under this Agreement are set out in Annex 3 and its Appendices.

Article 6
Modification of Concessions

1. The Parties shall not nullify or impair any of the concessions under this Agreement, except in cases provided for in this Agreement.

2. Nothing in this Agreement shall preclude any Party from negotiating and entering into arrangements to accelerate the implementation of concessions made under this Agreement or to incorporate new goods into such concessions, provided that such arrangements are mutually agreed upon and applied to all the other Parties.

3. Any Party may, by negotiation and agreement with any other Party to which it has made a concession, modify or withdraw such concession made under this Agreement. In such negotiations and agreement, which may include provision for compensatory adjustment with respect to other goods, the Parties concerned shall maintain a general level of reciprocal and mutually advantageous concessions not less favourable to trade than that provided for in this Agreement prior to such agreement.

4. Any agreement by the Parties to modify or withdraw concessions made in the tariff reduction or elimination programme in accordance with paragraph 3, or to accelerate the elimination of tariffs in such programme or to incorporate goods into such programme in accordance with paragraph 2, shall supersede any tariff rate or track determined pursuant to the tariff reduction or elimination programme for that good as set out in Annexes 1 and 2, shall be treated as an amendment to the relevant Annexes and shall enter into force in accordance with the procedure under Article 17.

Article 7
WTO Disciplines

Subject to the provisions of this Agreement and any future agreements as may be agreed pursuant to the reviews of this Agreement by the Parties under Article 15, the Parties[1] hereby agree and reaffirm their commitments to abide by the provisions of the WTO disciplines as set out in Annexes 1A and 1C to the WTO Agreement, as listed in Annex 4, which include, among others, non-tariff measures, technical barriers to trade (hereinafter referred to as "TBT"), sanitary and phytosanitary (hereinafter referred to as "SPS") measures, subsidies and countervailing measures, anti-dumping measures and intellectual property rights.

Article 8
Quantitative Restrictions and Non-Tariff Barriers and Sanitary and Phytosanitary Measures

1. Each Party undertakes not to adopt or maintain any prohibition or quantitative restriction on the importation of any goods of the other Parties or on the exportation of any goods destined for the territory of the other Parties, except in accordance with its WTO rights and obligations or other provisions in this Agreement.

2. Each Party shall ensure the transparency of its non-tariff measures that they are not prepared, adopted or applied with a view to or with the effect of creating unnecessary obstacles to trade among the Parties. The Parties shall identify non-tariff barriers other than quantitative restrictions for elimination as soon as possible after the entry into force of this Agreement. The timeframe for elimination of these non-tariff barriers shall be mutually agreed upon by all the Parties.

---

[1] Non-WTO Members of ASEAN shall abide by the WTO provisions in accordance with their accession commitments to the WTO.

3. The Parties recognises the importance of transparency of TBT and SPS regulations as in the WTO Agreements on TBT and SPS, including notification procedures on preparation for regulations and standards on TBT and on any occurrences of SPS incident to reduce their negative effect on trade as well as to protect human, animal or plant life or health. Each Party shall designate its contact point for the purpose of responding queries related to this Article.

4. A working group on TBT and SPS (hereinafter referred to as the "WG on TBT and SPS") under the Implementing Committee shall be established to deal with issues relating to the implementation of this Article and to facilitate trade and protect human, animal or plant life or health through mutual cooperation and bilateral consultations. The WG on TBT and SPS shall comprise of government officials from agriculture, fisheries, livestock and industry agencies and other related agencies. The WG on TBT and SPS shall develop its scope of work and meet at least once a year or as mutually agreed upon by the Parties.

Article 9
Safeguard Measures

1. Each Party which is a WTO member retains its rights and obligations under Article XIX of GATT 1994 and the WTO Agreement on Safeguards. Actions taken pursuant to Article XIX of GATT 1994 and the WTO Agreement on Safeguards shall not be subject to the Agreement on Dispute Settlement Mechanism under the Framework Agreement.

2. With regard to ASEAN-Korea FTA safeguard measures, a Party shall have the right to initiate such a measure on a good within the transition period for that good. The transition period for a good shall begin from the date of entry into force of this Agreement and end seven (7) years from the date of completion of tariff reduction/elimination for that good.

3. Subject to the following paragraphs of this Article, a Party shall be free to take ASEAN-Korea FTA safeguard measures if as an effect of the obligations incurred by the Party under this Agreement, including tariff concessions, or, if as a result of unforeseen developments and of the effects of the obligations incurred by the Party, a good is being imported from the other Parties to which tariff concession was made for that good in such increased quantities, absolute or relative to domestic production, and under such conditions so as to substantially cause or threaten to cause serious injury to the domestic industry of the importing Party that produces like or directly competitive goods in its territory.

4. If an ASEAN-Korea FTA safeguard measure is taken, a Party taking such a measure may:

(a) suspend the further reduction of any rate of tariff provided for under this Agreement for the good; or

(b) increase the tariff rate on the good concerned to a level not to exceed the lesser of:

(i) the applied MFN tariff rate on the good in effect at the time the action is taken; and

(ii) the applied MFN tariff rate on the good in effect on the day immediately preceding the date of entry into force of this Agreement.

5. Any ASEAN-Korea FTA safeguard measure may be maintained for an initial period of up to three (3) years and may be extended for a period not exceeding one year if it is determined pursuant to the procedures referred to in paragraph 6 that the measure continues to be necessary to prevent or remedy serious injury and to facilitate adjustment and that there is evidence that the domestic industry is adjusting. Notwithstanding the duration of an ASEAN-Korea FTA safeguard measure on the good, such a measure shall terminate at the end of the transition period for that good.

6. In applying ASEAN-Korea FTA safeguard measures, the Parties shall adopt the rules for the application of safeguard measures, including provisional measures, as provided under the WTO Agreement on Safeguards, with the exception of the quantitative restriction measures set out in Article 5, and Articles 9, 13, and 14 of the WTO Agreement on Safeguards. As such, all other provisions of the WTO Agreement on Safeguards shall, *mutatis mutandis*, be incorporated into and form an integral part of this Agreement.

7. An ASEAN-Korea FTA safeguard measure shall not be applied against a good originating in the territory of a Party, so long as its share of imports of the good concerned in the importing Party does not exceed 3% of the total imports from the Parties.

8. In seeking compensation under Article 8 of the WTO Agreement on Safeguards for an ASEAN-Korea FTA safeguard measure, the Parties concerned shall seek the good offices of the Implementing Committee to determine the substantially equivalent level of concessions to that existing under this Agreement between the Party taking the safeguard measure and the exporting Parties which would be affected by such a measure prior to any suspension of equivalent concessions. Any proceedings arising from such

good offices shall be completed within ninety (90) days from the date on which the ASEAN-Korea FTA safeguard measure was applied.

9. On a Party's termination of an ASEAN-Korea FTA safeguard measure on a good, the tariff rate for that good shall be the rate that, according to that Party's tariff reduction and elimination programme as provided in Annexes 1 and 2, would have been in effect but for the measure.

10. Notwithstanding the provisions of this Article, no Party may impose an ASEAN-Korea FTA safeguard measure on a good to which actions are being applied pursuant to Article XIX of GATT 1994 and the WTO Agreement on Safeguards. When a Party intends to apply, pursuant to Article XIX of GATT 1994 and the WTO Agreement on Safeguards, an action on a good to which ASEAN-Korea FTA safeguard measure is being applied, it shall terminate the ASEAN-Korea FTA safeguard measure prior to the imposition of the action to be applied pursuant to Article XIX of GATT 1994 and the WTO Agreement on Safeguards.

11. All official communications and documentations exchanged among the Parties and to the Implementing Committee relating to any ASEAN-Korea FTA safeguard measures shall be in writing and shall be in the English language.

Article 10
Measures to Safeguard the Balance of Payments

Where a Party is in serious balance of payments and external financial difficulties or threat thereof, it may, in accordance with GATT 1994, which includes the Understanding on Balance-of-Payments Provisions of GATT 1994, adopt restrictive import measures. In adopting such measures, the Party shall immediately consult with the other Parties.

Article 11
General Exceptions

Subject to the requirement that such measures are not applied in a manner which would constitute a means of arbitrary or unjustifiable discrimination among the Parties where the same conditions prevail, or a disguised restriction on international trade, nothing in this Agreement shall be construed to prevent the adoption or enforcement by a Party of measures:

(a) necessary to protect public morals;

(b) necessary to protect human, animal or plant life or health;

(c) relating to the importations or exportations of gold or silver;

(d) necessary to secure compliance with laws or regulations which are not inconsistent with the provisions of this Agreement, including those relating to customs enforcement, the enforcement of monopolies operated under paragraph 4 of Article II and Article XVII of GATT 1994, the protection of patents, trademarks and copyrights, and the prevention of deceptive practices;

(e) relating to the products of prison labour;

(f) imposed for the protection of national treasures of artistic, historic or archaeological value;

(g) relating to the conservation of exhaustible natural resources if such measures are made effective in conjunction with restrictions on domestic production or consumption;

(h) undertaken in pursuance of the obligations under any intergovernmental commodity agreement which conforms to criteria submitted to the WTO and not disapproved by it or which is itself so submitted and not so disapproved;

(i) involving restrictions on exports of domestic materials necessary to ensure essential quantities of such materials to a domestic processing industry during periods when the domestic price of such materials is held below the world price as part of a governmental stabilisation plan, provided that such restrictions shall not operate to increase the exports of or the protection afforded to such domestic industry, and shall not depart from the provisions of this Agreement relating to non-discrimination; and

(j) essential to the acquisition or distribution of products in general or local short supply, provided that any such measures shall be consistent with the principle that all Parties are entitled to an equitable share of the international supply of such products, and that any such measures, which are inconsistent with the other provisions of this Agreement shall be discontinued as soon as the conditions giving rise to them have ceased to exist.

Article 12
Security Exceptions

Nothing in this Agreement shall be construed:

(a) to require any Party to furnish any information the disclosure of which it considers contrary to its essential security interests;

(b) to prevent any Party from taking any action which it considers necessary for the protection of its essential security interests, including but not limited to:

  (i) action relating to fissionable materials or the materials from which they are derived;

  (ii) action relating to the traffic in arms, ammunition and implements of war and to such traffic in other goods and materials as is carried on directly or indirectly for the purpose of supplying a military establishment;

  (iii) action taken so as to protect critical communications infrastructure from deliberate attempts intended to disable or degrade such infrastructure;

  (iv) action taken in time of war or other emergency in domestic or international relations; or

(c) to prevent any Party from taking any action in pursuance of its obligations under the United Nations Charter for the maintenance of international peace and security.

Article 13
Regional and Local Government

In fulfilling its obligations and commitments under this Agreement, each Party shall ensure their observance by regional and local governments and authorities in its territory as well as their observance by non-governmental bodies in the exercise of powers delegated by central, regional or local governments or authorities within its territory.

Article 14
Institutional Arrangements

The institutions as provided for in Article 5.3 of the Framework Agreement shall oversee, supervise, coordinate and review, as appropriate, the implementation of this Agreement.

Article 15
Review

1. The AEM+Korea or their designated representatives shall meet within one year of the date of entry into force of this Agreement and then biennially or otherwise as appropriate to review this Agreement for the purpose of considering further measures to liberalise trade in goods as well as develop disciplines and negotiate agreements on matters referred to in Article 7 or any other relevant matters as may be agreed.

